# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទ សហគមន៍កំពង់ប្រាក់

## រយៈពេល៣ឆ្នាំ

## (២០១៤ - ២០១៦)

| | |
|---|---|
| សហគមន៍នេសាទ | : កំពង់ប្រាក់ |
| ភូមិ | : កំពង់ប្រាក់ បេង និងក្រាំងវែង |
| ឃុំ | : ស្នាអន្សា |
| ស្រុក | : ក្រគរ |
| ខេត្ត | : ពោធិ៍សាត់ |

## មាតិកា
## ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍


**១-ស្ថានភាពទូទៅ**

**២-អំពីប្រជាសាស្ត្រ**

ក- ប្រជាពលរដ្ឋ

ខ-មុខរបរ

**៣-កន្លែងនេសាទសហគមន៍ និងធនធានដែលមាននៅក្នុងកន្លែងនេសាទសហគមន៍**

ក-ទីតាំង

ខ-ដែននេសាទ

គ-តំបន់ដែលមានលទ្ធភាពបង្កើតកន្លែងអភិរក្ស

ឃ-ធនធានជលផល

**៤-ការធ្វើនេសាទ**

ក-អ្នកនេសាទ

ខ-ឧបករណ៏នេសាទ

គ-ការប៉ាន់ប្រមាណផលចាប់បានប្រចាំឆ្នាំ

**៥-ផែនការគ្រប់គ្រងសហគមន៍នេសាទ**

**ក-ទស្សនៈវិស័យ**

**ខ-គោលបំណង**

**គ-ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍**

គ១-ផែនការប្រើប្រាស់ឧបករណ៍នេសាទ

គ២-ផែនការកែលំអដែននេសាទ

គ៣-ផែនការរៀបចំកន្លែងអភិរក្ស

គ៤-ផែនការគ្រប់គ្រងព្រៃលិចទឹក

គ៥-ផែនការចុះល្បាតទប់ស្កាត់បទល្មើសនេសាទ

គ៦-ផែនការផ្សព្វផ្សាយច្បាប់ជលផល និងលិខិតបទដ្ឋានផ្សេងៗពាក់ព័ន្ធ

គ៧-ផែនការបណ្តុះបណ្តាល

គ៨-ផែនការអភិវឌ្ឍវារីវប្បកម្មក្នុងសហគមន៍

គ៩-ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍសហគមន៍

**ឃ.ផែនការយុទ្ធសាស្ត្រ**

**-តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៏រយៈពេល៣ឆ្នាំ**

**-តារាងកម្មវិធីការងារ**

**-តារាងឧបសម្ព័ន្ធ**

# ផែនការគ្រប់គ្រង
# កន្លែងនេសាទសហគមន៍

## ១-ស្ថានភាពទូទៅ

សហគមន៍នេសាទត្រូវបានបង្កើតឡើងដោយមហាសន្និបាតកំណើតដំបូង នៅថ្ងៃទី ៦ ខែតុលា ឆ្នាំ២០០៦ និងបានធ្វើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ លើកទី២ ចុះថ្ងៃទី…….. ខែ............. ឆ្នាំ២០.......... ។

សហគមន៍នេសាទ **កំពង់ប្រាក់** មានទីតាំងស្ថិតនៅក្នុងភូមិកំពង់ប្រាក់ ភូមិបេង និងភូមិក្រាំងវែង ឃុំស្នាអន្សា ស្រុកក្រគរ ខេត្តពោធិ៍សាត់ ដែលមានសមាជិកសរុប ចំនួន២៣៨ នាក់ ស្រីចំនួន១១៩ នាក់ និងមានគណៈកម្មការចំនួន១១នាក់ ស្រីគ្មាន ។ ក្នុងនោះចំនួនគ្រួសារសរុប ៣៨៣ គ្រួសារ ។

កន្លងមកសហគមន៍នេសាទនេះបានដំណើរការសកម្មភាពសំខាន់ៗរបស់ខ្លួន រួមមាន៖

-ចុះល្បាតត្រួតពិនិត្យដែននេសាទសហគមន៍

-ប្រជុំពិភាក្សាកំណត់ព្រំប្រទល់ដែននេសាទសហគមន៍

-ចុះកំណត់ព្រំប្រទល់ដែននេសាទសហគមន៍

-ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងធនធានជលផល

-ទស្សនៈកិច្ចសិក្សានៅសហគមន៍នេសាទភ្លៀតកោះពងសត្វ ខេត្តបន្ទាយមានជ័យ

-ចូលរួមប្រជុំជាមួយភូមិ ឃុំ

-រៀបចំបញ្ជីឈ្មោះសមាជិកសហគមន៍នេសាទ

-រៀបចំលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ

-រៀបចំធ្វើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍

-ចិញ្ចឹមត្រី(ពិសោធន៍) ក្នុងបែ ចំនួន២គ្រួសារ

-ប្រមូលព័ត៌មានទូទៅសំរាប់ធ្វើផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

## ២-អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ក -ប្រជាសាស្ត្រ

-ចំនួនប្រជាពលរដ្ឋសរុបនៅក្នុងសហគមន៍មានចំនួននាក់១៩៧៥នាក់ ស្រី១០៤៤នាក់ ក្នុងនោះមានជនជាតិខ្មែរចំនួន១៩៧៥ នាក់ អាណិកជនវៀតណាមចំនួន ០០ នាក់ ។

-ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមាន ១២ នាក់

-ចំនួនស្ត្រីពោះម៉ាយក្នុងសហគមន៍នេសាទមាន ០២ នាក់

-ចំនួនជនពិការក្នុងសហគមន៍នេសាទមាន ០៤ នាក់ ស្រី០២នាក់

-ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមាន ៣១នាក់ ស្រី២៣នាក់

-ចំនួនកុមារកំព្រាក្នុងសហគមន៍នេសាទចំនួន ៧នាក់ ស្រី៣នាក់

-ចំនួនអ្នកជម្ងឺរ៉ាំរ៉ៃក្នុងសហគមន៍នេសាទមាន ១៤ នាក់ ស្រី ០៩ នាក់

-ប្រជាពលរដ្ឋក្នុងសហគមន៍នេសាទជាអ្នកកាន់សាសនាព្រះពុទ្ធ ១០០% ។

-ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៍នេសាទទាំងអស់អ្នកមិនចេះអក្សរមានចំនួន៣៤៦នាក់ ស្រី ១៩១ កម្រិតថ្នាក់បឋមសិក្សាចំនួន៤៤៣នាក់ ស្រី២០៤ នាក់ កម្រិតមធ្យមសិក្សា៦៩នាក់ ស្រី២៧នាក់ ។

**ខ-មុខរបរ**

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេះរួមមាន៖

-ធ្វើនេសាទចំនួន ២១៦ គ្រួសារ

| | | |
|---|---|---|
| -ធ្វើស្រែ | ចំនួន | ២៦៥ គ្រួសារ ទំហំ ៥២៦ ហិកតា |
| - ដាំបន្លែ | ចំនួន | ៦៧ គ្រួសារ លើក្បូន៨គ្រួសារ និងដីទំហំ ០,៩២ ហិកតា |
| -ជាងផ្ទះ ជាងទូក | ចំនួន | ០៤ គ្រួសារ |
| -លក់ដូរ និងទិញលក់ផលនេសាទ | ចំនួន | ១៨ គ្រួសារ |
| -ចិញ្ចឹមសត្វ | ចំនួន | ១៧៩ គ្រួសារ (ជ្រូក មាន់ ទា) ជាលក្ខណៈគ្រួសារ |
| -លក់កំលាំងពលកម្ម | ចំនួន | ១៧ គ្រួសារ |
| -ចិញ្ចឹមត្រី | ចំនួន | ៥៦ គ្រួសារ (ចំនួន៣៨បែ និង ១ស្រះ) |
| -ធ្វើសិប្បកម្ម | ចំនួន | ១០២ គ្រួសារ (ត្បាញកន្ទេល - បង្គី) |
| -កែច្នៃផលនេសាទ | ចំនួន | ៣៣ គ្រួសារ |
| -ម៉ាស៊ីនបោកបែនស្រូវ | ចំនួន | ០៣ គ្រួសារ |
| -កិនស្រូវ | ចំនួន | ២៩ គ្រួសារ |
| -លក់នំ | ចំនួន | ០៩ គ្រួសារ |
| -ចិញ្ចឹមគោ | ចំនួន | ៨៣ គ្រួសារ |
| -ចិញ្ចឹមក្របី | ចំនួន | ១២៦ គ្រួសារ |
| -គ្រូ | ចំនួន | ០៦ គ្រួសារ |
| -ធ្វើកម្មករកាត់ដេរ | ចំនួន | ១២៣ គ្រួសារ |
| -ឡើងត្នោត ធ្វើស្ករ | ចំនួន | ០៥ គ្រួសារ |

## ៣-កន្លែងនេសាទសហគមន៍ និងធនធានដែលមាននៅក្នុងនេសាទសហគមន៍

**ក-ទីតាំង**

កន្លែងនេសាទសហគមន៍កំពង់ប្រាក់ មានទំហំ ២៣៩៤ ហិចតា ជាកន្លែងដែលមានដែននេសាទតាមប្រឡាយ បឹងបួរ ព្រែក និងព្រៃលិចទឹក ដើម្បីធ្វើការគ្រប់គ្រង ថែរក្សាការពារ អភិរក្ស និងអភិវឌ្ឍ ដោយមាននិយាមការដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង។

មានព្រំប្រទល់៖

-ខាងកើតទល់នឹងភូមិជ្រលង ឃុំអន្លង់ត្នោត

-ខាងលិចទល់នឹងភូមិចុងខ្នុង ឃុំអូរសណ្តាន់

-ខាងជើងទល់នឹងកន្លែងអភិរក្សជលផល កំពង់ប្រាក់

-ខាងត្បូងទល់នឹងភូមិវាលវង់ និងភូមិសារវន្ត ឃុំស្នាអន្សា

**ខ-ដែននេសាទ**

កន្លែងនេសាទសហគមន៍ **កំពង់ប្រាក់** មាន៖

| | | | |
|---|---|---|---|
| -បឹងទន្លេសាប | ទំហំ៤៣៥,១៧ | ហិកតា | នៃសាទពេញមួយឆ្នាំ |
| -បឹងអណ្តូងតូច | ទំហំ ០,១៣ | ហិកតា | តំបន់អភិរក្ស |
| -បឹងអណ្តូងធំ | ទំហំ ១,៣៧ | ហិកតា | តំបន់អភិរក្ស |
| -បឹងក្របីស្លាប់ | ទំហំ ១,១១ | ហិកតា | នៃសាទពេញមួយឆ្នាំ |
| -បឹងកំពង់សិលា | ទំហំ ០,៩៣ | ហិកតា | នៃសាទពេញមួយឆ្នាំ |
| -បឹងទឹកថ្លា | ទំហំ ០,០៧ | ហិកតា | ពីខែកញ្ញា ដល់ខែមិនា |
| -បឹងច្រាំងខ្ពស់ | ទំហំ ០,២២ | ហិកតា | នៃសាទពេញមួយឆ្នាំ |
| -បឹងទទឹងថ្ងៃ | ទំហំ ០,២៤ | ហិកតា | នៃសាទពេញមួយឆ្នាំ |
| -បឹងអន្លៀមអក | ទំហំ ០,៨០ | ហិកតា | នៃសាទពេញមួយឆ្នាំ |
| -បឹងតាព្រហ្មលើ | ទំហំ ០,២៨ | ហិកតា | នៃសាទពេញមួយឆ្នាំ |
| -បឹងតាព្រហ្មក្រោម | ទំហំ ០,៣២ | ហិកតា | នៃសាទពេញមួយឆ្នាំ |
| -បឹងខ្នាចលាភលើ | ទំហំ ០,៤៤ | ហិកតា | នៃសាទពេញមួយឆ្នាំ |
| -បឹងខ្នាចលាភក្រោម | ទំហំ ០,០៩ | ហិកតា | ខែកញ្ញា ដល់ខែមិនា |
| -បឹងខ្នាចតាព្រហ្ម | ទំហំ ០,២២ | ហិកតា | ខែកញ្ញា ដល់ខែមិនា |
| -បឹងត្នោតតាចាន់ | ទំហំ ០,៤០ | ហិកតា | ខែកញ្ញា ដល់ខែមិនា |
| -បឹងសាឡិត | ទំហំ ០,៧៤ | ហិកតា | ខែកញ្ញា ដល់ខែមិនា |
| -បឹងផ្ទោលលើ | ទំហំ ០,១២ | ហិកតា | នៃសាទពេញមួយឆ្នាំ |
| -បឹងផ្ទោលក្រោម | ទំហំ ០,២៥ | ហិកតា | នៃសាទពេញមួយឆ្នាំ |
| -បឹងខ្នាចចក | ទំហំ ០,៣ | ហិកតា | នៃសាទពេញមួយឆ្នាំ |
| -បឹងខ្នាចយៀវ | ទំហំ ០,០៧ | ហិកតា | ខែកញ្ញា ដល់ខែមិនា |
| -បឹងខ្លាខ្វា | ទំហំ ០,១៣ | ហិកតា | ខែកញ្ញា ដល់ខែមិនា |
| -បឹងលាងជើងលើ | ទំហំ ០,០៣ | ហិកតា | ខែកញ្ញា ដល់ខែមិនា |
| -បឹងលាងជើងក្រោម | ទំហំ ០,០២ | ហិកតា | ខែកញ្ញា ដល់ខែមិនា |
| -បឹងប្រវែងទទឹង | ទំហំ ២,៩៩ | ហិកតា | នៃសាទពេញមួយឆ្នាំ |
| -បឹងត្រពាំងក្អារ | ទំហំ ០,២៦ | ហិកតា | នៃសាទពេញមួយឆ្នាំ |
| -បឹងត្រពាំងត្រស់ | ទំហំ ០,០៩ | ហិកតា | នៃសាទពេញមួយឆ្នាំ |
| -បឹងថ្ក | ទំហំ ០,០៩ | ហិកតា | នៃសាទពេញមួយឆ្នាំ |
| -បឹងក្រចាប | ទំហំ ០,០៩ | ហិកតា | ខែកញ្ញា ដល់ខែមិនា |
| -បឹងចង្រ្កានដែក | ទំហំ ១,៥ | ហិកតា | នៃសាទពេញមួយឆ្នាំ |
| -ព្រែកកំពង់ប្រាក់ | ទំហំ ១៣,៨ | ហិកតា (ប១៥០០ម៉ែត្រ ទ ១៥ ម៉ែត្រ) | នៃសាទពេញមួយឆ្នាំ |

**គ-តំបន់ដែលមានលទ្ធភាពបង្កើតកន្លែងអភិរក្ស**

-បឹងអណ្តូងតូច ទំហំ ០,១៣ ហិកតា

-បឹងអណ្តូងធំ ទំហំ ១,៣៧ ហិកតា

-ដីទំនាបព្រៃលិចជុំវិញបឹងអណ្តូងតូច-អណ្តូងធំទំហំ ៧៧ ហិកតា

**ឃ-ធនធានជលផល**

**-ប្រភេទត្រី**:

ត្រីរស់ ត្រីព្រួល ត្រីប្រា ត្រីឆ្លាំង ត្រីកេស ត្រីឆ្ពោក ត្រីក្អែក ត្រីត្រសក់ ត្រីគល់រាំង ត្រីរៀល ត្រីកញ្ចុះ ត្រីលិញ ត្រីក្រាញ់ ត្រីចង្វារ ត្រីផ្ទោង ត្រីឆ្ដូញ ត្រីពោធិ៍ ត្រីអាចម៍កុក ត្រីស្លឹកឬស្សី ត្រីកន្ត្រប់ ខ្លាំងក្រាយ ត្រីខ្មាន់ ត្រីកន្ធរ ត្រីក្រឡង់ ត្រីសណ្ដាយ ត្រីអណ្ដែង ត្រីដំរី ត្រីតាអោន ត្រីក្រម៉ម ត្រីស្លាត ត្រីកំភ្លៀវ ត្រីខ្នឹង ត្រីគ្រុំ ត្រីឈ្មៀត ត្រីកញ្ជ្រូក ត្រីបណ្ដូលអំពៅ ត្រីច្រកែង ត្រីកាហែ ត្រីស្រកាវក្ដាម ត្រីឆ្ពិន ត្រីព្រលូង កំពឹស ត្រីកំពត ត្រីក្រពាត់ ត្រីក្រុះ ត្រីកញ្ចាញ់ច្រាស ត្រីកំព្រាម ត្រីក្បក ត្រីក្បាន្ត ត្រីកញ្ចាក់ខ្លា ត្រីឆ្មា ត្រីដងខ្វែង ត្រីប្រម៉ា ត្រីអង្កត់ប្រាក់ ត្រីអណ្ដាតឆ្កែ ។ល។

**-ប្រភេទវារីសត្វ**:

អណ្ដើកសកល អណ្ដើកស្រែ អណ្ដើកក្បាលធំ អណ្ដើកបិទមុខ ឆ្មាដាវ ពស់ ខ្យងគូចស្រួច ខ្យងគូចទាល ខ្យងថៃ(ខ្យងពណ៌លឿង) ក្ដាម អន្ទង់ ខ្ទៅគូចស្រួច ខ្ទៅគូចទាល កង្កែប កន្ធាយ ឈ្លើង គ្រុំ លៀស អន្ទង់ ។ល។

**-ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ**:

ដើមថ្លើមអណ្ដើក អូយយ៉ាស់(បន្លាយយួន) បន្លាស្អិត ប្របួយមេ ប្របួយឈ្មោល ដើមទន្លា ដើមក្រពៅ ដើមសណ្ដាន់ ដើមម្ដេញ ដើមសន្ទែ ដើមខ្ទំ ដើមសង្ឃរ ដើមព្រីងបាយ ដើមដៃខ្លា ដើមរាំងដើមអញ្ចាញ ត្រស់ វល្លិ៍ដូនព្រះ វល្លិ៍ត្អើក ស្លាបទា កន្ទាំងហែ ក្រថៅ វល្លិ៍អណ្ដាតត្រកួត ក្រចាប់ សារាយសាប សារាយជូ កំប្លោក ចកតូច ចកធំ ចកបាយទា កំពីងពួយស កំពីងពួយក្រហម ត្រកួន ព្រលិតអាចមន៍មាន់ ព្រលិតដូង រំចង់ ត្រាវអណ្ដែត ស្មៅអន្ទក់ទឹក ស្មៅអំពៅខៀប កំប្លង កក់ជ្រុង កក់ក្ដាម ឈូក ចន្ទល់ភ្នំ កញ្ឆែត ស្មៅថ្នក់ទឹក ភ្លងទឹក ។ល។

## ៤-ការធ្វើនេសាទ

### ក-អ្នកនេសាទ

-អ្នកនេសាទជាសមាជិកសហគមន៍ ចំនួន ២៣៨ នាក់ ស្រី១១៩នាក់

-អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទ នៅក្នុងសហគមន៍មានចំនួន ៦៣ នាក់ ស្រី៣៥នាក់

-អ្នកនេសាទមិនមែនជាសមាជិកដែលមកពីខាងក្រៅសហគមន៍មានចំនួន ៣០០នាក់ ស្រី៧២នាក់

### ខ.ឧបករណ៍នេសាទ

-ឧបករណ៍នេសាទ និងទូកកាណូតរបស់សមាជិកសហគមន៍នេសាទ

| ប្រភេទ ឧបករណ៍ | ឯកតា | ចំនួន ឧបករណ៍ | ប្រវែង /ទំហំ | រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....) |
|---|---|---|---|---|
| មង | ម៉ែត្រ | ៨១ទូក (៧០០ម/ទូក) | ៥៦.៧០០ម× ២,៥ស.ម×(0,0២៥ម-0,១ម) | ពេញមួយឆ្នាំ |
| សន្ទូចរនង | ផ្លែ | ៤២ទូក (៣៥00ផ្លែ/ទូក) | ១៤៧.000ផ្លែ (ផ្លែលេខ១២ , ១៣) | មិថុនា ដល់ មិនា |

| | | | | |
|---|---|---|---|---|
| បង្គៃ | ផ្លែ | ២៨ទូក(៥០ផ្លែ/ទូក) | ១.៤០០ផ្លែ (ផ្លែលេខ៩) | តុលា ដល់ មករា |
| សំណាញ់ | វង់ | ៤៨វង់(១វង់/ទូក) | ៤៨វង់x៣ម-៥ម×( ក្រឡា0,0២ម-0,0៤ម) | ពេញមួយឆ្នាំ |
| អួន | វង់ | ៨វង់ (១វង់=១០០ម/ទូក) | ៨០០ម× ៣ម× (0,0២៥ម-0,0៣ម) | ធ្នូ ដល់ មិថុនា |
| លបទល់/វ៉ាវ | គ្រឿង | ៣២ទូក(៥០គ/ទូក) | ១.៦០០គx0,៧មx១,៧ម ×0,0៤ម-0,0៥ម (លប២ប្រើរបាំងព្រួល៥ម) | កក្កដាដល់មិនា |
| លបលួង | គ្រឿង | ៤ទូក(៤០គ/ទូក) | ១៦០គx0,៤មx១ម | មេសា ដល់ មិថុនា |
| លបត្រីស្លួញ | គ្រឿង | ៣ទូក(៥គ/ទូក) | ១៥គx0,៤មx0,៨ម | មិថុនា ដល់ តុលា |
| ទ្រូ | គ្រឿង | ១៦គ្រួសារ(២គ/គ្រួ) | ៣៨គx0,៨មx១,២ម | មិថុនា ដល់ ធ្នូ |
| ជនរុញដៃ | គ្រឿង | ៤៩គ(១គ/ទូក) | ៤៩គx២,៥មx៣មx0,0១៥ម | វិច្ឆិកា ដល់ មិថុនា |
| លាន់ | គ្រឿង | ១០ទូក (១០០គ/ទូក) | ១.000គx0,0៨មx២ម | មិថុនា ដល់ ធ្នូ |
| អង្រុត | គ្រឿង | ៥០គ(១គ/នាក់) | ៥០គ | វិច្ឆិកា ដល់ ឧសភា |
| កន្សំ | ដុំ | ៣០ទូក (១០០ដុំ/ទូក) | ៣.000ដុំ | មេសា ដល់ មិថុនា |
| ថ្នង | គ្រឿង | ៣០គ(១គ/នាក់) | ៣០គx២,៥មx៣មx0,0១៥ម | មេសា ដល់ មិថុនា |

| **ប្រភេទទូក កាណូត** | **ចំនួន** | **ចំណុះ** | **កំលាំងសេះ** |
|---|---|---|---|
| ទូក | ១៥០ គ្រឿង | ៥០-២៧០គីឡូក្រាម | |
| កាណូត | ៧០ គ្រឿង | ១៥០-៥០០គីឡូក្រាម | ៦,៥-២៤ សេស |

-ឧបករណ៍នេសាទ និងទូកកាណូតរបស់អ្នកនៅក្នុងតំបន់ប៉ុន្តែមិនមែនជាសមាជិកសហគមន៍នេសាទ

| **ប្រភេទ ឧបករណ៍** | **ឯកតា** | **ចំនួនឧបករណ៍** | **ប្រវែង /ទំហំ** | **រដូវប្រើប្រាស់ឧបករណ៍ (ខែ....ដល់ខែ....)** |
|---|---|---|---|---|
| មង | ម៉ែត្រ | ១ទូក(៧០០ម/ទូក) | ៩.៨០០ម× ២,៥ម×(0,0២៥ម-0,១ម) | ពេញមួយឆ្នាំ |
| សន្ទូចរនង | ផ្លែ | ៤២ទូក (៣៥០០ផ្លែ/ទូក) | ១៤៧.000ផ្លែ (ផ្លែលេខ១២ , ១៣) | មិថុនា ដល់ មិនា |
| បង្គៃ | ផ្លែ | ៥ទូក(៥០ផ្លែ/ទូក) | ២៥០ផ្លែ (ផ្លែលេខ៩) | តុលា ដល់ មករា |
| សំណាញ់ | វង់ | ១០វង់(១វង់/នាក់) | ១០វង់x៣ម-៥ម×( ក្រឡា0,0២ម-0,0៤ម) | ពេញមួយឆ្នាំ |
| អួន | វង់ | ២វង់ (១វង់=១០០ម/ទូក) | ២០០ម× ៣ម× (0,0២៥ម-0,0៣ម) | ធ្នូ ដល់ មិថុនា |
| លបទល់/វ៉ាវ | គ្រឿង | ៤ទូក(៥០គ/ទូក) | ២០០គ្រx0.៧មx១,៧ម ×0,0៤ម-0,0៥ម (លប២ប្រើរបាំងព្រួល៥ម) | កក្កដាដល់មិនា |
| លបលួង | គ្រឿង | ១ទូក៤០គ្រ/ទូក= | ៤០គ្រx0,៤មx១ម | មេសា ដល់ មិថុនា |
| លបត្រីស្លួញ | គ្រឿង | ១ទូក(៥គ្រ/ទូក) | ៥គx0,៤មx0,៨ម | មិថុនា ដល់ តុលា |
| ទ្រូ | គ្រឿង | ៤គ្រួសារ | ៨គ្រx0,៨មx១,២ម | មិថុនា ដល់ ធ្នូ |

| | | | | |
|---|---|---|---|---|
| | | (២គ្រ/គ្រួសារ) | | |
| ជនរុញដៃ | គ្រឿង | ៣នាក់(១គ្រ/នាក់) | ៣គ្រx២,៥មx៣មx០,០១៥ម | វិច្ឆិកា ដល់ មិថុនា |
| លាន់ | គ្រឿង | ៥ទូក(១០០គ្រ/ទូក) | ៥០០គ្រx០,០៨មx២ម | មិថុនា ដល់ ធ្នូ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេស |
|---|---|---|---|
| ទូក | ៨០គ្រឿង | ១០០-១៥០គីឡូក្រាម | |
| កាណូត | ២២ គ្រឿង | ៣០០-១.០០០គីឡូក្រាម | ៦,៥-២៤ សេស |

-ឧបករណ៍នេសាទ និងទូកកាណូតរបស់អ្នកមកពីក្រៅសហគមន៍នេសាទ

| ប្រភេទ ឧបករណ៍ | ឯកតា | ចំនួនឧបករណ៍ | ប្រវែង /ទំហំ | រដូវប្រើប្រាស់ឧបករណ៍ (ខែ….ដល់ខែ….) |
|---|---|---|---|---|
| មង | ម៉ែត្រ | ៥០ទូក (១៤០០ម/ទូក) | ៧០.០០០ម×២មx ០,០០៨ម-០,០៦ម | ពេញមួយឆ្នាំ |
| សន្ទូច | ផ្លែ | ១៦ទូក (២០០០ផ្លែ /ទូក) | ៣២.០០០ផ្លែ(ផ្លែលេខ១២ , ១៣) | មីនាដល់មិថុនា |
| អួន | វង់ | ៣០ទូក (១០០ម /ទូក) | ៣.០០០មx៤ម-៦មx០,០២៥ម- ០,០៤ម | មីនាដល់មិថុនា |
| សៃយ៉ឺន កំពឹស | គ្រឿង | ១៥ទូក (៤០០គ្រ /ទូក) | ៦.០០០គ្រឿងx០,២ម×០,៣ម | ពេញមួយឆ្នាំ |
| លបត្រីស្លួញ | គ្រឿង | ៥ទូក(១០០គ្រ / ទូក) | ៥០០គ្រឿង x០,១៨ម× ០,៥ម | មិថុនាដល់វិច្ឆិកា |
| សំណាញ់ | វង់ | ៧០ទូក(១វង់ / ទូក) | ៧០វង់x៥ម-១២មx ក្រឡា០,០២ម-០,០៤ម | មករា ដល់ មិថុនា |
| ឡើត្រី កំភ្លាញ | គ្រឿង | ៦ទូក(១០០គ្រ /ទូក) | ៦០០គ្រឿងx ០,៥ម× ០,៨ម | កក្កដា ដល់មករា |
| សាង ចាក់ត្រី | គ្រឿង | ១០នាក់(១គ្រ / នាក់) | ១០គ្រឿង(មិនរួមជំរុំកែវឆ្លុះ) | កញ្ញា ដល់ធ្នូ |
| ឆ្នុក | គ្រឿង | ១៥ទូក(១គ្រ / ទូក) | ១៥គ្រឿងx១៨មx១៨មx០,០០៨ម-០,០១២ម | កញ្ញា ដល់ធ្នូ |
| លូស្បៃមុង | គ្រឿង | ១៥ទូក(៤គ្រ /ទូក) | ១៥គ្រឿង x៥ម-៦មx០,៧ម | ពេញមួយឆ្នាំ |
| ឆក់ | គ្រឿង | ៤០នាក់(១គ្រ / នាក់) | ៤០គ្រឿង | ពេញមួយឆ្នាំ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូក | ៨២ | ១០០-២០០គីឡូក្រាម | |
| ទូកមានម៉ាស៊ីន | ៧០ - ១០០គ្រឿង | ១៥០-១.៥០០គីឡូក្រាម | ៦,៥ -៣៥ សេស |

គ.ការប៉ាន់ប្រមាណផលនេសាទចាប់ប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំឆ្នាំក្នុងមួយគ្រួសារ (គិតជាគីឡូក្រាម) | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |

| | | | |
|---|---|---|---|
| ត្រីចំរុះ | ១.៨៩២ គីឡូក្រាម | ៣៨០ គីឡូក្រាម | ២.២៧២ គីឡូក្រាម |

## ៥-ផែនការគ្រប់គ្រងសហគមន៍នេសាទ

### ក-ទស្សនៈវិស័យ

សហគមន៍នេសាទ **កំពង់ប្រាក់** មានទស្សនៈវិស័យរួមចំណែកគ្រប់គ្រងធនធានជលផលប្រកបដោយសមធម៌ និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

### ខ-គោលបំណង

-ចូលរួមគ្រប់គ្រងដែននេសាទទឹកសាបដែលបានលុប ឬកាត់បន្ថយពីឡូត៍នេសាទ កន្លែងនេសាទគ្រួសារដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬសហគមន៍ធ្វើនេសាទ កន្លែងនេសាទបំរុង ទំនាបលិចទឹកក្នុងរដូវតំឡើង នាទីព្រៃលិចទឹក ។

-ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តភាព និងធានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌។

-ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍ តាមតយៈការអភិវឌ្ឍន៍ចំរុះដោយមានការចូលរួម

-ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ ហើយនិងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់លើធនធានធម្មជាតិ។

### គ-ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

#### គ១-ផែនការប្រើប្រាស់ឧបករណ៍នេសាទ

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺរៀបចំឡើងដោយគិតគូរអំពីប្រភេទដែននេសាទ ទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ។

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលា | ឧបករណ៍នេសាទអនុញ្ញាតឲ្យប្រើ | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ប្រភេទ | ប្រវែង/ទំហំ | ចំនួនឧបករណ៍ | |
| បឹងទន្លេសាប | ពេញមួយឆ្នាំ | មង | ៨០ទូកx១០០មx០,០២៥ម-០,១២ម x២,៥ម-៥ម | ៨.០០០ម៉ែត្រ | រដូវបិទនេសាទ |
| | កញ្ញាដល់ឧសភា | | ៨០ទូកx៧០០មx០,០២៥ម-០,១២មx២,៥ម-៥ម | ៥៦.០០០ ម៉ែត្រ | រដូវបើកនេសាទ |
| | ពេញមួយឆ្នាំ | សន្ទូចរនង | ២០ទូកx១៥០០ផ្លែ (លេខ១២,១៣) | ៣០.០០០ផ្លែ | |
| | ពេញមួយឆ្នាំ | កន្សំ | ១៥ទូកx១០០ដុំ | ១.៥០០ដុំ | |
| | ពេញមួយឆ្នាំ | សំណាញ់ | ១៥ទូកx៦មx០,០២៥ម | ១៥វង់ | |
| | ពេញមួយឆ្នាំ | ថ្នងឬជន | ៥០ទូកx២,៥មx៣មx០,០១៥ម | ៥០គ្រឿង | |
| | ពេញមួយឆ្នាំ | លប | ១០ទូកx១០គ្រឿងx០,៧មx១,៧ម របាំងព្រួល៥ម×(០,០៤ម) | ១០០គ្រឿង | |

| | | | | | |
|---|---|---|---|---|---|
| | ពេញមួយឆ្នាំ | អួន | ៥ទូកx១០០មx៦មx0,0២៥ម | ៥00ម៉ែត្រ | |
| -បឹងក្របីស្លាប់<br>-បឹងកំពង់សិលា<br>-បឹងច្រាំងខ្ពស់<br>-បឹងទទឹងថ្ងៃ<br>-បឹងអន្សោមអក<br>-បឹងតាព្រហ្មលើ<br>-បឹងតាព្រហ្មក្រោម<br>-បឹងខ្នាចលាភលើ<br>-បឹងផ្ទោលលើ<br>-បឹងផ្ទោលក្រោម<br>-បឹងខ្នាចចក<br>-បឹងប្រវែងទទឹង<br>-បឹងត្រពាំងក្ដារ<br>-បឹងត្រពាំងត្រស់<br>-បឹងថ្កុ<br>-បឹងចង្ក្រានដែក<br>-ព្រៃកកំពង់ប្រាក់ | មករាដល់មីនា | មង | ៥ទូកx១០០មx0,0២៥ម-0,១២ម x១,៥ម | ៥00ម៉ែត្រ | បឹងទាំង ១៧នេះ ត្រូវបាន ប្រើប្រាស់ ឧបករណ៍ នេសាទ ចំនួន ,ទំហំ និងប្រវែង ដូចៗគ្នា |
| | | សំណាញ់ | ១៥ទូកx៦មx0,0២៥ម | ១៥វង់ | |
| | | ដូអន្ទង់ | ២ទូកx៣0គ្រឿងx0,២មx0,៨ម | ៦0គ្រឿង | |
| | មករាដល់កុម្ភៈ | លបលួង | ៥ទូកx២0គ្រឿងx0,៥មx0,៧មx 0,0២៥ម | ១00គ្រឿង | |
| | | អង្រុត | ៧ទូកx១គ្រឿងx0,៥មx 0,0១៥ម | ៧គ្រឿង | |
| | | ជនរុញដៃ | ១0ទូកx១គ្រឿងx២,៥មx៣មx 0,0១៥ម | ១0គ្រឿង | |
| | មករាដល់មីនា | អួន | ២ទូកx១វង់x២៥មx៣មx 0,0២៥ម | ២វង់ | |
| | | | | | |
| -បឹងទឹកថ្លា<br>-បឹងខ្នាចលាភក្រោម<br>-បឹងខ្នាចតាព្រហ្ម<br>-បឹងត្នោតតាចាន់<br>-បឹងសាឡិត<br>-បឹងខ្នាចយៀវ<br>-បឹងខ្លាខ្វា<br>-បឹងលាងជើងលើ<br>-បឹងលាងជើងក្រោម<br>-បឹងក្រចាប | ខែកញ្ញាដល់មីនា | មង | ៥ទូកx១០០មx0,0២៥ម-0,១២ម x១,៥ម | ៥00ម៉ែត្រ | បឹងទាំង១0 នេះទឹករីង អស់ចាប់ពី ខែមេសា រហូតដល់ ខែសីហា |

**គ២-ផែនការកែលំអដែននេសាទ**

| ឈ្មោះដែន នេសាទ | ទំហំ(ហ.ត) | ទំហំដែលត្រូវ កែលំអ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្ដើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| បឹងអណ្ដូងតូច<br>បឹងអណ្ដូងធំ | ១,៥ហត | ខ្នងលើ២ម xបាត៤ម x កំពស់១,៥មxប្រវែង១៥ម | ធ្វើទំនប់បង្ងៀរ | មីនា/២០១៤ | មិថុនា/២០១៤ |

| | | | | | |
|---|---|---|---|---|---|
| ព្រែកកំពង់ប្រាក់ | ០,៧៥ហត | ប=៥០០មxទ=១៥មx ជ=១ម =៧.៥០០ម$^{៣}$ | ស្តារថ្មីឡើងវិញ | មីនា/២០១៥ | កក្កដា/២០១៥ |

### គ៣-ផែនការរៀបចំកន្លែងអភិរក្ស

| ឈ្មោះដែននេសាទ | ទំហំ(ហ.ត) | ប្រភេទនៃការអភិរក្ស | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| បឹងអណ្តូងតូច,ធំ | ១,៥ ហិកតា | អភិរក្សត្រីមេពូជ | ផ្សព្វផ្សាយពីកន្លែងអភិរក្សនិងការហាមឃាត់ដល់ប្រជាពលរដ្ឋឱ្យបានទូលំទូលាយ ២ដង/ឆ្នាំ | ខែមករានិងវិច្ឆិកា /២០១៤ | ខែមករានិងវិច្ឆិកា /២០១៦ |
| | | | ល្បាតជាប្រចាំកន្លែងអភិរក្ស | ពេញបីឆ្នាំ | |
| | | | -បោះបង្គោលស៊ីម៉ង់ព្រំប្រទល់កន្លែងអភិរក្សត្រីមេពូជសហគមន៍ចំនួន១០ដើម<br>-ធ្វើស្លាកសញ្ញាហាមឃាត់២ផ្ទាំង | ខែឧសភា/២០១៤ | ខែមិថុនា/២០១៤ |
| ព្រៃលិចទឹកជុំវិញបឹងអភិរក្សអណ្តូងតូចនិងបឹងអណ្តូងធំ | ៧៧ ហិកតា | អភិរក្សព្រៃលិចទឹក | យាមល្បាត, ការពារ | ពេញបីឆ្នាំ | |
| | | | -ដាក់ស្លាក៤<br>-អប់រំផ្សព្វផ្សាយ(២ដង/ឆ្នាំ) | -ខែឧសភា/ ២០១៤<br>- ខែមករានិងវិច្ឆិកា /២០១៤ | - ខែមិថុនា/២០១៤<br>- ខែមករានិងវិច្ឆិកា /២០១៤ |

### គ៤-ផែនការគ្រប់គ្រងព្រៃលិចទឹក

| ឈ្មោះដែននេសាទ | ទំហំ(ហ.ត) | ប្រភេទកូនឈើដែល ត្រូវដាំនិងការពារ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ខ្នាចលាភលើ, ក្រោម | ៦ហិកតា | ព្រៃដាំដុះឡើងវិញ | បណ្តុះនិងដាំកូនរាំង, គ្រស់ ,សណ្តាន់ចំនួន ១៥.០០០ដើម | ខែមករា/២០១៤ | ខែមិថុនា/២០១៤ |
| | ៧ហិកតា | | បណ្តុះនិងដាំកូនរាំង, គ្រស់,សណ្តាន់ចំនួន ១៧.៥០០ដើម | ខែមករា/២០១៥ | ខែមិថុនា/២០១៥ |
| | ៧ហិកតា | | បណ្តុះនិងដាំកូនរាំង, គ្រស់,សណ្តាន់ចំនួន ១៧.៥០០ដើម | ខែមករា/២០១៦ | ខែមិថុនា/២០១៦ |

| | | | | | |
|---|---|---|---|---|---|
| ព្រៃលិចទឹកជុំវិញ<br>-បឹងត្រពាំងក្ពារ<br>-បឹងថ្ក<br>-បឹងក្រចាប<br>-បឹងខ្លាចចក<br>-បឹងខ្លាខ្វា<br>-បឹងត្រពាំងត្រស់ | -១១ហិកតា<br>-១៥ហិកតា<br>-១០ហិកតា<br>-២០ហិកតា<br>-១០ហិកតា<br>-១៣ហិកតា | ព្រៃការពារ<br>និងប្រើប្រាស់ | ផ្សព្វផ្សាយអំពីការប្រើប្រាស់ព្រៃលិចទឹកដល់ប្រជាពលរដ្ឋគ្រប់រូបដែលរស់នៅក្នុងនិង ក្រៅសហគមន៍នេសាទ | ខែមករា/២០១៤ | ខែមករា/២០១៦ |
| | | | យាមល្បាត, ការពារ | ជាប្រចាំ | |
| | | | ដាក់ស្លាក ០២ផ្ទាំង | ខែមករានិងវិច្ឆិកា<br>/២០១៤ | ខែមករានិងវិច្ឆិកា<br>/២០១៦ |
| | | | ប្រើប្រាស់ព្រៃលិចទឹកគ្រប់ប្រភេទឲ្យមាននិរន្តភាព | ជាប្រចាំ | |

**គ៥-ផែនការចុះល្បាតទប់ស្កាត់បទល្មើសនេសាទ**

ផែនការចុះទប់ស្កាត់បទល្មើសនេសាទត្រូវបានរៀបចំដូចខាងក្រោម:

| សកម្មភាព | លទ្ធផលរំពឹងទុក | ចំណាយ<br>ដុល្លា | អ្នកចូលរួម | ថ្ងៃ ខែ ឆ្នាំ<br>ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ<br>បញ្ចប់ |
|---|---|---|---|---|---|
| ប្រជុំពិភាក្សាគណៈកម្មការសហគមន៍នេសាទរៀបចំផែនការប្រចាំត្រីមាស ឆមាស ឆ្នាំ | -គណៈកម្មការទទួលបាននូវបទពិសោធន៍ល្អៗនិងចាត់វិធានការសមស្របក្នុងការចុះអនុវត្តការងារ | ១.០៨០<br>ដុល្លា | គណៈកម្មការ<br>សមាជិកស.ន | ខែ១និងខែ៦/<br>២០១៤<br>(រៀងរាល់ឆ្នាំ) | ខែ១និងខែ៦/<br>២០១៤ |
| ផ្សព្វផ្សាយពីច្បាប់ជលផលថ្មី ច្បាប់បទដ្ឋាននានាដែលពាក់ព័ន្ធ និងចំណេះដឹងបរិស្ថានដល់ប្រជាពលរដ្ឋ២ដង/ឆ្នាំ | សមាជិកសហគមន៍នេសាទ និងប្រជាពលរដ្ឋក្នុងនិងក្រៅសហគមន៍ចូលរួមការពារ ថែរក្សានិងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយសមធម៌ និងការបំផ្លិចបំផ្លាញធនធានត្រូវបានថយចុះ | | គណៈកម្មការ<br>សមាជិកស.ន<br>អ្នកពាក់ព័ន្ធ<br>អាជ្ញាធរ<br>និងជំនាញ | ខែមេសានិង<br>តុលា<br>/២០១៤<br>(រៀងរាល់ឆ្នាំ) | ខែមេសានិង<br>តុលា<br>/២០១៤ |
| -ទំនាក់ទំនងនិងសហការជាមួយអាជ្ញាធរមូលដ្ឋាននិងស្ថាប័នជំនាញពាក់ព័ន្ធ<br>-រៀបចំកំលាំងចុះបង្ក្រាបដល់ទីកន្លែង | -មានការចូលរួមពីអាជ្ញាធរ និងជំនាញពាក់ព័ន្ធ<br>-បទល្មើសនេសាទថយចុះ និងឈានទៅលុបបំបាត់ទាំងស្រុង<br>-ធនធានជលផលកើនឡើង<br>-ជីវភាពប្រជាពលរដ្ឋធូរធារ | ៤.៩២០<br>ដុល្លា | | ជាប្រចាំ<br>រយៈពេល<br>៣ឆ្នាំ | |

**គ៦-ផែនការផ្សព្វផ្សាយច្បាប់ជលផល និងលិខិតបទដ្ឋានផ្សេងៗពាក់ព័ន្ធ**

ផែនការផ្សព្វផ្សាយច្បាប់ជលផល លិខិតបទដ្ឋានផ្សេងៗ លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ផែនការគ្រប់គ្រង កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ និងផែនការប្រើប្រាស់ឧបករណ៍នេសាទត្រូវបានរៀបចំឡើងដូចខាងក្រោម :

| **សកម្មភាព** | **លទ្ធផលរំពឹងទុក** | **ចំណាយ ដុល្លា/រៀល** | **អ្នកចូលរួម** | **ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម** | **ថ្ងៃ ខែ ឆ្នាំ បញ្ចប់** |
|---|---|---|---|---|---|
| -ប្រជុំ<br>-ផ្សព្វផ្សាយតាមមីក្រូ<br>-ផ្សព្វផ្សាយតាមរយៈចែកឯកសារ | ប្រជាពលរដ្ឋទាំងសមាជិកស,ន អ្នកមិនមែនជាសមាជិកស,នបានយល់ដឹង , មានការចូលរួមនិងអនុវត្តតាម | ៣.៦០០ ដុល្លា | គណៈកម្មការ,សមាជិកស.ននិងអ្នកក្រៅ ស.ន<br>អាជ្ញាធរមូលដ្ឋាន<br>ជំនាញជលផល,<br>អង្គការដៃគូរ | (ម្តង /ឆ្នាំ)<br>ខែមេសា/ ២០១៤ | ខែមេសា/ ២០១៦ |

**គ៧-ផែនការបណ្តុះបណ្តាល**

ផែនការបណ្តុះបណ្តាលត្រូវបានរៀបចំឡើងដូចខាងក្រោម :

| **សកម្មភាព** | **លទ្ធផលរំពឹងទុក** | **ចំណាយ ដុល្លា/រៀល** | **អ្នកចូលរួម** | **ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម** | **ថ្ងៃ ខែ ឆ្នាំ បញ្ចប់** |
|---|---|---|---|---|---|
| សិក្ខាសាលាពីរបៀបសរសេរ :<br>-របាយការណ៍<br>-កំណត់ហេតុ<br>-គម្រោងស្នើសុំថវិកា<br>-គម្រោងថវិកា | ប្រជាពលរដ្ឋទាំងសមាជិកស,ន អ្នកមិនមែនជាសមាជិកស,នបានយល់ដឹង និងអាចអនុវត្តបាន ក្នុងការងារជាក់ស្តែង | ២.៥០០ ដុល្លា | គណៈកម្មការស.ន<br>អាជ្ញាធរមូលដ្ឋាន<br>សិស្ស,និស្សិត | (ម្តង /ឆ្នាំ)<br>ខែមករា/ ២០១៤ | ខែមករា/ ២០១៦ |
| បច្ចេកទេសបណ្តុះកូនឈើ | មានចំណេះដឹង និងបទពិសោធន៍ បណ្តុះនិងដាំកូនឈើព្រៃលិចទឹក | ៣០០ ដុល្លា | គណៈកម្មការ និង សមាជិកស.ន.ក.ព.ប | ខែមករា/ ២០១៤ | ខែមករា/ ២០១៤ |
| បច្ចេកទេសចិញ្ចឹមត្រី :<br>-ចិ.ក្នុងបៃ(ប្រា,អណ្តែង)<br>-ចិ. ក្នុងស្រះ(ប្រា, ទីឡាព្យ៉ា, អណ្តែង , ក្រាញ់) | មានចំណេះដឹង និងបទពិសោធន៍ក្នុងការចិញ្ចឹមត្រី និងអាចអនុវត្តបាន | ៧០០ ដុល្លា | គណៈកម្មការ និង សមាជិកស.ន.ក.ព.ប | ខែកុម្ភៈ/ ២០១៤ | ខែកុម្ភៈ/ ២០១៤ |

**គ៨-ផែនការអភិវឌ្ឍវារីវប្បកម្មក្នុងសហគមន៍**

ផែនការសម្រាប់អភិវឌ្ឍវារីវប្បកម្មក្នុងសហគមន៍ត្រូវបានរៀបចំឡើងដូចខាងក្រោម :

| **ប្រភេទវារីវប្បកម្ម** | **ចំនួន** | **ប្រភេទ កូនត្រីពូជ** | **បរិមាណ កូនត្រីពូជ** | **ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម** | **ថ្ងៃ ខែ ឆ្នាំ ប្រមូលផល** |
|---|---|---|---|---|---|

| | | | | | |
|---|---|---|---|---|---|
| -ចិញ្ចឹមត្រីតាមបែ | ២០បx៤មx២មx១,៥ម | ត្រីអណ្តែង (៦០៛០/កូន) | ៦០០០កូន/ឆ្នាំ | ខែសីហា/ ២០១៤<br>ខែសីហា/ ២០១៥<br>ខែសីហា/ ២០១៦ | ខែកុម្ភៈ/ ២០១៥<br>ខែកុម្ភៈ/ ២០១៦<br>ខែកុម្ភៈ/ ២០១៧ |
| | ៥បx៤មx២មx១,៥ម | ត្រីប្រា (១២០៛/កូន) | ៦០០០កូន/ឆ្នាំ | ខែសីហា/ ២០១៤<br>ខែសីហា/ ២០១៥ | ខែមិថុនា/ ២០១៥<br>ខែមិថុនា/ ២០១៦ |
| -ចិញ្ចឹមត្រីតាមស្រះ | ៣សx១៥មx១០មx៣,៥ម | ត្រីទីឡាព្យ៉ា (៤០៛០/កូន) | ៨០០០កូន/ឆ្នាំ | ខែសីហា/ ២០១៤<br>ខែសីហា/ ២០១៥<br>ខែសីហា/ ២០១៦ | ខែកុម្ភៈ/ ២០១៥<br>ខែកុម្ភៈ/ ២០១៦<br>ខែកុម្ភៈ/ ២០១៧ |
| | ៥សx១៥មx១០មx៣,៥ម | ត្រីប្រា | ៥០០០កូន/ឆ្នាំ | ខែសីហា/ ២០១៤<br>ខែសីហា/ ២០១៥ | ខែមិថុនា/ ២០១៥<br>ខែមិថុនា/ ២០១៦ |
| | ២សx១៥មx១០មx៣,៥ម | ត្រីក្រាញ់ (៥០៛០/កូន) | ៨០០០កូន/ឆ្នាំ | ខែសីហា/ ២០១៤<br>ខែសីហា/ ២០១៥<br>ខែសីហា/ ២០១៦ | ខែកុម្ភៈ/ ២០១៥<br>ខែកុម្ភៈ/ ២០១៦<br>ខែកុម្ភៈ/ ២០១៧ |

**គ៩-ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍសហគមន៍**

ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍសហគមន៍ត្រូវបានរៀបចំឡើងដូចខាងក្រោម :

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំ ចាប់ផ្តើម | ថ្ងៃខែឆ្នាំ ចាប់បញ្ចប់ | ចំណូល សរុប | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានពីសមាជិកភាពសហគមន៍នេសាទ | -ផ្សព្វផ្សាយជ្រើសរើសសមាជិក និងបង់ប្រាក់សមាជិកភាព<br>-ប្រមូលភាគទាន ១០០០រៀល/ម្នាក់ | ខែមករា/២០១៤ | ខែធ្នូ/២០១៦ | ២៣៨.០០០ រៀល | ១០០០រៀល/នាក់ ២៣៨នាក់ |
| ភាគទានប្រចាំឆ្នាំ | -ផ្សព្វផ្សាយជូនដំណឹងដល់សមាជិកបង់ប្រាក់ភាគទានប្រចាំឆ្នាំ<br>-ប្រមូលភាគទានប្រចាំឆ្នាំ ២០០០រៀល/ម្នាក់ | ខែមីនា និងមិថុនា /២០១៤ រៀងរាល់ឆ្នាំ | ខែមីនា និង មិថុនា /២០១៦ | ១.៤២៨.០០០ រៀល | ២០០០រៀល/នាក់ ២៣៨នាក់ រាល់ឆ្នាំ រយៈពេល៣ឆ្នាំ |
| ប្រាក់ចំណូលពីអ្នកនេសាទមកពីក្រៅបង់ភាគទានអាជីវកម្មនេសាទ | -ផ្សព្វផ្សាយជូនដំណឹងដល់សមាជិកក្រៅស.ន.ក.ព.ប បង់ប្រាក់ភាគទានអាជីវកម្មនេសាទ<br>-ប្រមូលភាគទានអាជីវកម្មនេសាទ | ខែមករា/២០១៤ (ជាប្រចាំ) | ខែធ្នូ/២០១៦ | ៤.៥០០.០០ រៀល | ៥០០០រៀល/នាក់ ៣០០ទូក រាល់ឆ្នាំ រយៈពេល៣ឆ្នាំ |

| | | | | | |
|---|---|---|---|---|---|
| | ៥០០០រៀល/ទូក | | | | |
| សរសេរគម្រោងស្នើសុំថវិកាពីរដ្ឋាភិបាល និងអង្គការដៃគូរ | -ទំនាក់ទំនងជាមួយរដ្ឋបាលជលផល , អាជ្ញាធរ និង អង្គការដៃគូរ<br>-សរសេរគម្រោងស្នើសុំថវិកា | ខែ៥ ដល់ ខែ៧ /២០១៤ (រៀងរាល់ឆ្នាំ) | ខែ៥ដល់ខែ៧ /២០១៤ | ៥០.០០០$ | |

## ឃ.យុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំ ដូចខាងក្រោម :

-បង្កើតគណៈកម្មការសម្រាប់អនុវត្តតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការ រួមមាន: សមាជិក គណៈកម្មការសហកមន៍នេសាទ ចាស់ទុំដែលមានបទពិសោធន៍និងចំណេះដឹងល្អៗជាពិសេសបញ្ហានេសាទ

-ស្នើសុំជំនួញបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់ចំពោះផែនការណាដែលទាក់ទងនិងបច្ចេកទេសជលផលដូចជា ការធ្វើផែនការកន្លែងអភិរក្សមេពូជត្រី ការរៀបចំកន្លែងអភិរក្ស ព្រៃលិច ទឹក កន្លែងអភិរក្សជីវៈចម្រុះ ការស្តារព្រៃក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី ការរកថវិកាទ្រទ្រង់ជាដើម

-រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញអង្គការនានា គម្រោង និងម្ចាស់ជំនួយដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិការសម្រាប់ដំណើរការអនុវត្តផែនការ

-រៀបចំផែនការអនុវត្តផែនការតាមដំណាក់កាលនិមួយៗដោយជាក់លាក់

-ទាក់ទងជាមួយរដ្ឋបាលជលផលដើម្បីសុំការគាំទ្រថវិការ និងជួយរកដៃគូសម្រាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហាគមន៍នេសាទ

-ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហកមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ

-កៀងគរការចូលរួមចំណែករបស់សមាជិកសហាគមន៍នេសាទ

-រៀបចំវិធានការណ៏ចំពោះអ្នកនេសាទមកពីខាងក្រៅសហាគមន៍

-ពង្រឹងសមត្ថភាពបច្ចេកទេស និង គ្រប់គ្រងរបស់គណៈកម្មការសហាគមន៍នេសាទ

-ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តផែនការ

-រៀបចំទិញសម្ភារៈសម្រាប់ប្រើប្រាស់នៅក្នុងសហាគមន៍ GPS ០១គ្រឿង និងម៉ាស៊ីនថតរូប០១គ្រឿង

-បញ្ចូលផែនការគ្រប់គ្រងសហាគមន៍នេសាទទៅក្នុងផែនការអភិវឌ្ឍឃុំ ។

## រាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍កំពង់ប្រាក់
## រយៈពេល៣ឆ្នាំ (២០១៤ ដល់ ២០១៦)

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ (រៀល) | ប្រភពជំនួយ | ពេលចាប់ផ្តើម | ពេលបញ្ចប់ |
|---|---|---|---|---|---|---|
| ១-ការប្រើប្រាស់ឧបករណ៍នេសាទ | ប្រជុំផ្សព្វផ្សាយអំពីផែនការប្រើប្រាស់ឧបករណ៍នេសាទ១ដង/ឆ្នាំ(តារាងស្តីពីទីតាំង ប្រភេទ ទំហំ ឧបកណ៍ពេលវេ-លាចាប់ផ្តើមនិងបញ្ចប់ធ្វើអាជីវកម្មនេសាទរបស់សហគមន៍នេសាទកំពង់ប្រាក់) | -សមសជិកសហគមន៍នេសាទ និងអ្នកខាងក្រៅមានការយល់ ដឹង និងអនុវត្តតាម<br>-សមាជិកនិងប្រជាពលរដ្ឋចូលរួមអនុវត្តតាមផែនការប្រើប្រាស់ឧបករណ៍នេសាទសហគមន៍<br>-ផលត្រីនៅក្នុងសហកមន៍មានការកើនឡើងប្រជាពលរដ្ឋអាចរកត្រីបានពេញមួយឆ្នាំនាំឲ្យជីវភាពធូរធារ | ៣.៦០០ដុល្លា | សហគមន៍<br>អង្គការដៃគូ<br>អាជ្ញាធរ<br>រដ្ឋបាលជលផល | រាល់ខែ៤/២០១៤ | រាល់ខែ ៤/២០១៦ |
| | បិទផ្សាយឯកសារផែនការប្រើប្រាស់ឧបករណ៍នេសាទសហគមន៍១ដង/ឆ្នាំ | | | | រាល់ខែ៤/ ២០១៤ | រាល់ខែ ៤/២០១៦ |
| | ចែកចាយឯកសារផែនការប្រើប្រាស់ឧបករណ៍ដល់អ្នកនេសាទ១ដង/ឆ្នាំ | | | | រាល់ខែ៤/ ២០១៤ | រាល់ខែ ៤/២០១៦ |
| | ផ្សព្វផ្សាយតាមមេក្រូនូវផែនការប្រើប្រាស់ឧបករណ៍នេសាទដង/ឆ្នាំ | | | | រាល់ខែ៤/២០១៤ | រាល់ខែ ៤/២០១៦ |
| ២-ការកែលំអដែននេសាទ | ធ្វើទំនប់បង្ខៀរ(បេតុង)កន្លែងអភិរក្សត្រីមេពូជបឹងអណ្តូងតូច-អណ្តូងធំ | -ផលស្តុកមច្ឆជាតិកើនឡើង<br>-មច្ឆជាតិសំបូរឡើងវិញ<br>-ជីវចម្រុះកើនឡើង<br>-ព្រៃលិចទឹកនៅគង់វង់ | ៧០០០ដុល្លា | សហគមន៍<br>អង្គការដៃគូ<br>អាជ្ញាធរ<br>រដ្ឋបាលជលផល | ខែ៣/២០១៤ | ខែ៦/២០១៦ |
| | ស្តារព្រែកកំពង់ប្រាក់ | -ធ្វើឲ្យមានបរិស្ថានល្អគុណភាពទឹកល្អប្រសើរឡើងវិញ<br>-មច្ឆជាតិសំបូរឡើងវិញ<br>-ប្រជាពលរដ្ឋធ្វើចរាចរតាមផ្លូវទឹកបានងាយស្រួល | ១២០០០ដុល្លា | សហគមន៍<br>អង្គការដៃគូ<br>អាជ្ញាធរ<br>រដ្ឋបាលជលផល | ខែ៣/២០១៥ | ខែ៧/២០១៥ |

| | | | | | | |
|---|---|---|---|---|---|---|
| ៣-ផែនការរៀបចំកន្លែងអភិរក្ស | ផ្សព្វផ្សាយពីកន្លែងអភិរក្ស ដល់ប្រជាពលរដ្ឋឱ្យបានទូលំទូលាយ ២ដង/ឆ្នាំ | សមាជិកសហគមន៍នេសាទ និងប្រជាពលរដ្ឋក្នុងនិងក្រៅ សហគមន៍ចូលរួមថែរក្សាការពារ | ៧.៥០០ដុល្លា | សហគមន៍ អង្គការដៃគូ អាជ្ញាធរ រដ្ឋបាលជលផល | ខែមករានិងវិច្ឆិកា /២០១៤ | ខែមករានិងវិច្ឆិកា /២០១៦ |
| | ល្បាត និងហាមឃាត់ជាប្រចាំកន្លែងអភិរក្ស | សមាជិកក្រុមល្បាតចូលរួម ល្បាតតាមផែនការ | ២.០០០ដុល្លា | សហគមន៍ | ជាប្រចាំ | ជាប្រចាំ |
| | បោះបង្គោលស៊ីម៉ង់ព្រំប្រទល់កន្លែងអភិរក្សត្រីមេពូជសហគមន៍ចំនួន១០ដើម<br>-ធ្វើស្លាកសញ្ញាហាមឃាត់០២ផ្ទាំង | -ប្រជាពលរដ្ឋទាំងអស់ក្នុងសហគមន៍បានយល់ដឹងអំពីកន្លែងអភិរក្សត្រីមេពូជ។<br>-ផលត្រីនឹងមានការកើនឡើង សមាជិកសហគមន៍នេសាទ និងប្រជាពលរដ្ឋក្នុងនិងក្រៅ សហគមន៍ចូលរួមថែរក្សាការពារ | ១២០ដុល្លា/ដើម<br>១០០ដុល្លា /ផ្ទាំង | សហគមន៍ អង្គការដៃគូ អាជ្ញាធរ រដ្ឋបាលជលផល | ខែឧសភា/២០១៤ | ខែមិថុនា/២០១៤ |
| ៤-ផែនការគ្រប់គ្រងព្រៃលិចទឹក | -បណ្ដុះនិងដាំកូនរាំង,ត្រស់ សណ្ដាន់ចំនួន១៥០០០ដើម | -ព្រៃលិចទឹកមានឡើងវិញ<br>-ជាជម្រកត្រី និងជីវចម្រុះពង កូន និងរកចំណី<br>-កាត់បន្ថយការហូរច្រោះដី<br>-កាត់បន្ថយការប្រែប្រួលអាកាសធាតុ | ៧.៥០០ដុល្លា (២០០០រ០/ដើម) | សហគមន៍ អង្គការដៃគូ អាជ្ញាធរ រដ្ឋបាលជលផល | -ខែមករា/២០១៤ | -ខែមិថុនា/២០១៤ |
| | - បណ្ដុះនិងដាំកូនរាំង,ត្រស់ សណ្ដាន់ចំនួន១៧៥០០ដើម | | ៨.៧៥០ដុល្លា | | -ខែមករា/២០១៥ | -ខែមិថុនា/២០១៥ |
| | -បណ្ដុះនិងដាំកូនរាំង,ត្រស់ សណ្ដាន់ចំនួន១៧៥០០ដើម | | ៨.៧៥០ដុល្លា | | -ខែមករា/២០១៦ | -ខែមិថុនា/២០១៦ |
| | -អប់រំផ្សព្វផ្សាយអំពីការប្រើប្រាស់ព្រៃលិចទឹកប្រកបដោយនិរន្តរភាព (២ដង/ឆ្នាំ) | -ស្គាល់តំបន់ព្រៃច្បាស់លាស់<br>-យល់ដឹងការប្រើប្រាស់ព្រៃលិចទឹក ប្រកបដោយនិរន្តរភាព | **តម្លៃ**រួមជាមួយការផ្សព្វផ្សាយនៅក្នុងផែនការរៀបចំកន្លែងអភិរក្ស | | ខែមករា និងខែវិច្ឆិកា /២០១៤ (រៀងរាល់ឆ្នាំ) | - ខែមករា ខែវិច្ឆិកា /២០១៤ |
| | ដាក់ស្លាក ០២ផ្ទាំង | ស្គាល់ច្បាស់តំបន់ព្រៃលិចទឹក | ១០០ដុល្លា/ផ្ទាំង | | ខែឧសភា/២០១៤ | ខែឧសភា/២០១៤ |

| | | | | | | |
|---|---|---|---|---|---|---|
| | យាមល្បាត, ការពារ | -ការកាប់បំផ្លាញ់ព្រៃលិចទឹកថយ<br>-ព្រៃលិចទឹកនៅបានគង់វង់ | ២.០០០ដុល្លា | | ពេញបីឆ្នាំ | ពេញបីឆ្នាំ |
| | ប្រើប្រាស់ព្រៃលិចទឹកគ្រប់ប្រភេទ | ព្រៃលិចទឹកគ្រប់ប្រភេទប្រើប្រាស់ជានិរន្តរភាព | | សហគមន៍ | ពេញមួយឆ្នាំ | |
| ៥-ការចុះល្បាតទប់ស្កាត់បទល្មើសនេសាទ | ប្រជុំពិភាក្សាគណៈកម្មការសហគមន៍នេសាទរៀបចំផែនការ | -គណៈកម្មការទទួលបាននូវបទពិសោធន៍ល្អៗនិងចាត់វិធានការសមស្របក្នុងការចុះអនុវត្តការងារ | ១.០៨០ដុល្លា | សហគមន៍<br>អង្គការដៃគូ<br>អាជ្ញាធរ<br>រដ្ឋបាលជលផល | ខែ១និងខែ៦/២០១៤<br>(រៀងរាល់ឆ្នាំ) | ខែ១និងខែ៦/២០១៤ |
| | ផ្សព្វផ្សាយពីច្បាប់ជលផលថ្មីច្បាប់បទដ្ឋាននានាដែលពាក់ព័ន្ធនិងចំណេះដឹងបរិស្ថានដល់ប្រជាពលរដ្ឋ២ដង/ឆ្នាំ | សមាជិកសហកមន៍នេសាទនិងប្រជាពលរដ្ឋក្នុងនិងក្រៅសហគមន៍ចូលរួមការពារ ថែរក្សានិងប្រើប្រាស់ធនធានធម្មជាតិប្រកបដោយសមធម៌និងការបំផ្លិចបំផ្លាញធនធានត្រូវបានថយចុះ | | | ខែមេសានិងតុលា<br>/២០១៤<br>(រៀងរាល់ឆ្នាំ) | ខែមេសានិងតុលា<br>/២០១៤ |
| | -ទំនាក់ទំនងនិងសហការជាមួយអាជ្ញាធរមូលដ្ឋាននិងស្ថាប័នជំនាញពាក់ព័ន្ធ<br>-រៀបចំកំលាំងចុះបង្ក្រាបដល់ទីកន្លែង | -មានការចូលរួមពីអាជ្ញាធរនិងជំនាញពាក់ព័ន្ធ<br>-បទល្មើសនេសាទថយចុះ និងឈានទៅលុបបំបាត់ទាំងស្រុង<br>-ធនធានជលផលកើនឡើង<br>-ជីវភាពប្រជាពលរដ្ឋធូរធារ | ៤.៩២០ដុល្លា | | ជាប្រចាំ<br>រយៈពេល ៣ឆ្នាំ | |
| ៦-ផែនការផ្សព្វផ្សាយច្បាប់ជលផលនិងលិខិតបទដ្ឋានផ្សេងៗពាក់ព័ន្ធ | -ប្រជុំ<br>-ផ្សព្វផ្សាយតាមមីក្រូ<br>-ផ្សព្វផ្សាយតាមរយៈ ចែកឯកសារ | ប្រជាពលរដ្ឋទាំងសមាជិកស,ន អ្នកមិនមែនជាសមាជិកស,ន បានយល់ដឹង , មានការចូលរួមនិងអនុវត្តតាម | ៣៦០០ ដុល្លា | សហគមន៍<br>អង្គការដៃគូ<br>អាជ្ញាធរ<br>រដ្ឋបាលជលផល | (ម្តង /ឆ្នាំ)<br>ខែមេសា/ ២០១៤ | ខែមេសា/២០១៦ |
| ៧-ផែនការបណ្តុះបណ្តាល | របៀបសរសេរ :<br>-របាយការណ៍ | ប្រជាពលរដ្ឋទាំងសមាជិកស,ន អ្នកមិនមែនជា | ២៥០០ ដុល្លា | | (ម្តង /ឆ្នាំ)<br>ខែមករា/ ២០១៤ | ខែមករា/២០១៤ |

| | | | | | | |
|---|---|---|---|---|---|---|
| | -កំណត់ហេតុ<br>-គម្រោងស្នើសុំថវិកា<br>-គម្រោងថវិកា | សមាជិកស,នបានយល់ដឹង និងអាចអនុវត្តបាន ក្នុងការងារជាក់ស្តែង | | សហគមន៍<br>អង្គការដៃគូ<br>អាជ្ញាធរ<br>រដ្ឋបាលជលផល | (រៀងរាល់ឆ្នាំ) | |
| | បច្ចេកទេសបណ្តុះ កូនឈើ | មានចំណេះដឹង និងបទ ពិសោធន៍ បណ្តុះនិងដាំ កូនឈើព្រៃលិចទឹក | ៣០០ ដុល្លា | | ខែមករា/ ២០១៤ | ខែមករា/ ២០១៤ |
| | បច្ចេកទេសចិញ្ចឹមត្រី :<br>-ចិ.ក្នុងបែ(ប្រា,អណ្តែង)<br>-ចិ. ក្នុងស្រះ(ប្រា, ទីឡា ព្យ៉ា, អណ្តែង , ក្រាញ់) | មានចំណេះដឹង និងបទ ពិសោធន៍ក្នុងការចិញ្ចឹមត្រី និងអាចអនុវត្តបាន | ៧០០ ដុល្លា | | ខែកុម្ភៈ/ ២០១៤ | ខែកុម្ភៈ/ ២០១៤ |
| ៨-ផែនការអភិវឌ្ឍវារីវប្បកម្មក្នុងសហគមន៍ | -ចិញ្ចឹមត្រីតាមបែ ចំនួន ២៥បែ : ត្រីអណ្តែង, ប្រា<br>- ចិញ្ចឹមត្រីតាមស្រះចំនួន១០ស្រះ : ត្រីទីឡាព្យ៉ា , ប្រា និងក្រាញ់ (សមាជិកស.ន.ក.ព.ប) | -សមាជិកស.ន.ក.ព.ប មានមុខរបរចិញ្ចឹមត្រីតាមបែ<br>-បានទទួលប្រាក់ចំណូល<br>-មានជីវភាពធូរធារ និងកាត់បន្ថយភាពក្រីក្រ | ៦០០ ដុល្លា | សមាជិក<br>(ស.ន.ក.ព.ប)<br>NGO<br>អាជ្ញាធរ<br>ស្ថាប័នជលផល | ខែសីហា/ ២០១៣<br>(រៀងរាល់ឆ្នាំ/៣ឆ្នាំ) | ខែមិថុនា/ ២០១៤ |
| ៩-ផែនការថវិកាទ្រទ្រង់សម្រាប់អភិឌ្ឍសហកមន៍ | -ផ្សព្វផ្សាយជ្រើសរើស សមាជិក និងបង់ប្រាក់សមាជិកភាព<br>-ប្រមូលភាគទាន ១.០០០រៀល/ម្នាក់<br>-ដើរប្រមូលភាគទានតាមផ្ទះ | -បានយល់ដឹងពីភាគទាន សមាជិកភាព និងមានការចូលរួម<br>-ភាគទានសមាជិកភាពសហគមន៍នេសាទ២៣៨នាក់(១.០០០៛/នាក់=២៣៨.០០០៛) | ៥៩,៥ ដុល្លា | សមាជិក<br>សហគមន៍<br>នេសាទ | ខែ១/២០១៤ | ខែ១២/២០១៦ |
| | -ផ្សព្វផ្សាយជូនដំណឹង ដល់សមាជិកបង់ប្រាក់ ភាគទានប្រចាំឆ្នាំ<br>-ប្រមូលភាគទានប្រចាំ ឆ្នាំ ២០០០រៀល/ម្នាក់ | -សមាជិកសហគមន៍និងចូលរួម បង់ភាគទានប្រចាំឆ្នាំរៀងរាល់ឆ្នាំ ចំនួន២៣៨នាក់(២.០០០៛/នាក់ =១.៤២៨.០០០៛) | ៣៥៧ ដុល្លា | សមាជិក<br>សហគមន៍<br>នេសាទ | ខែ៣និង៦(២០១៤) | ខែ៣និង៦(២០១៦) |
| | -ផ្សព្វផ្សាយជូនដំណឹង ដល់សមាជិកក្រៅស.ន.ក.ព.ប បង់ប្រាក់ ភាគទានអាជីវកម្ម នេសាទ | -សហគមន៍បានប្រាក់ចំណូលភាគទានអាជីវកម្មនេសាទពី អ្នកមកពីខាងក្រៅសហគមន៍នេសាទចំនួន | ១.១២៥ ដុល្លា | អ្នកមិនមែនជាសមាជិក និងអ្នកខាងក្រៅ | ខែ១/២០១៤ | ខែ១២/២០១៦ |

| | | | | | | |
|---|---|---|---|---|---|---|
| | -ប្រមូលភាគទាន អាជីវកម្មនេសាទ ៥០០០រៀល/ទូក | ៣០០ទូក | | | | |
| | -ទំនាក់ទំនងជាមួយរដ្ឋបាលជលផល , អាជ្ញាធរ និង អង្គការដៃគូ<br>-សរសេរគម្រោងស្នើ សុំថវិកា<br>-តាមដាន | -បានទទួលថវិការតាមគម្រោងសំណើ<br>-មានថវិកាសម្រាប់អនុវត្តផែនការសកម្មភាព | ៥០.០០០ ដុល្លា | អង្គការដៃគូ អាជ្ញាធរ ស្ថាប័នជលផល | ខែ៥ ដល់ ខែ៧ /២០១៤ (រៀងរាល់ឆ្នាំ) | ខែ៥ដល់ខែ៧ /២០១៤ |

# តារាងកម្មវិធីការងារ

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៤ | | | | | | | | | | | | ២០១៥ | | | | | | | | | | | | ២០១៦ | | | | | | | | | | | |
| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| **១- ការប្រើប្រាស់ឧបករណ៍នេសាទ** |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |
| ១-១ ប្រជុំផ្សព្វផ្សាយអំពីផែនការប្រើប្រាស់ឧបករណ៍ |  |  |  | → |  |  |  |  |  |  |  |  |  |  |  | → |  |  |  |  |  |  |  |  |  |  |  | → |  |  |  |  |  |  |  |  |
| ១-២ បិទផ្សាយឯកសារផែនការប្រើប្រាស់ឧបករណ៍នេសាទ |  |  |  | → |  |  |  |  |  |  |  |  |  |  |  | → |  |  |  |  |  |  |  |  |  |  |  | → |  |  |  |  |  |  |  |  |
| ១-៣ ផ្សព្វផ្សាយតាមមេក្រូ និងចែកឯកសារ |  |  |  | → |  |  |  |  |  |  |  |  |  |  |  | → |  |  |  |  |  |  |  |  |  |  |  | → |  |  |  |  |  |  |  |  |
| **២-ការកែលំអរដែននេសាទ** |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |
| ២-១ធ្វើទំនប់បង្ហៀរ(បេតុង)កន្លែងអភិរក្សបឹងអណ្តូងតូច-អណ្តូងធំ |  |  | → | → | → | → |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |
| ២-២ ស្តារដីល្បាប់ព្រែកកំពង់ប្រាក់ |  |  |  |  |  |  |  |  |  |  |  |  |  |  | → | → | → | → | → |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |
| **៣-ការរៀបចំកន្លែងអភិរក្ស** |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |
| ៣-១ ផ្សព្វផ្សាយពីកន្លែងអភិរក្ស | → |  |  |  |  |  |  |  |  |  | → |  | → |  |  |  |  |  |  |  |  |  | → |  | → |  |  |  |  |  |  |  |  |  | → |  |
| ៣-២ បោះបង្គោលព្រំប្រទល់ |  |  |  |  | → | → |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |
| ៣-៣ ធ្វើស្លាកសញ្ញាហាមឃាត់ |  |  |  |  | → | → |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |
| ៣-៤ ល្បាតជាប្រចាំកន្លែងអភិរក្ស | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → |
| **៤-ការរៀបចំកន្លែងអភិរក្ស** |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |
| ៤-១បណ្តុះ,ដាំកូនរាំង,ត្រស់,សណ្តាន់ |  |  |  |  |  | → |  |  |  |  |  |  |  |  |  |  |  | → |  |  |  |  |  |  |  |  |  |  |  | → |  |  |  |  |  |  |
| ៤-២អប់រំផ្សព្វផ្សាយពីការប្រើប្រាស់ព្រៃលិចទឹកប្រកបដោយនិរន្តរភាព | → |  |  |  |  |  |  |  |  |  | → |  | → |  |  |  |  |  |  |  |  |  | → |  | → |  |  |  |  |  |  |  |  |  | → |  |
| ៤-៣ដាក់ស្លាក ០២ផ្ទាំង |  |  |  |  | → |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |
| ៤-៤យាមល្បាត, ការពារ | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → |
| ៤-៥ប្រើប្រាស់ព្រៃលិចទឹកគ្រប់ប្រភេទប្រកបដោយនិរន្តរភាព | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → | → |
| **៥.ការចុះល្បាត និងទប់ស្កាត់បទល្មើសជលផល** |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |  |
| ៥.១ ផ្សព្វផ្សាយច្បាប់ជលផលថ្មី |  |  |  | → |  |  |  |  |  | → |  |  |  |  |  | → |  |  |  |  |  | → |  |  |  |  |  | → |  |  |  |  |  | → |  |  |
| ៥.២ ប្រជុំគណៈកម្មការរៀបចំ | → |  |  |  |  | → |  |  |  |  |  |  | → |  |  |  |  | → |  |  |  |  |  |  | → |  |  |  |  | → |  |  |  |  |  |  |

| | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ផែនការប្រចាំខែ ត្រីមាស | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៥.៣ទំនាក់ទំនងនិងសហការជាមួយស្ថាប័នជំនាញសមត្ថកិច្ចនិងសហគមន៍ជិតខាងចុះបង្ក្រាបបទល្មើសនេសាទ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| **៦.ផែនការផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ប្រជុំផ្សព្វផ្សាយ,ចាក់មីក្រូផ្សព្វផ្សាយនិងតាមរយៈ ចែកឯកសារ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| **៧.ផែនការបណ្តុះ បណ្តាល** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៧.១របៀបសរសេរ :របាយការណ៍កំណត់ហេតុ,គម្រោងស្នើសុំថវិកា គម្រោងថវិកា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៧.២បច្ចេកទេសបណ្តុះ និងដាំកូនព្រៃលិចទឹក | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៧.៣ បច្ចេកទេសចិញ្ចឹមត្រី :<br>-ចិ.ក្នុងបែ(ប្រា,អណ្តែង)<br>-ចិ. ក្នុងស្រះ(ប្រា, ទីឡាព្យ៉ា, អណ្តែង , ក្រាញ់) | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| **៨-ផែនការអភិវឌ្ឍវារី វប្បកម្ម** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៨.១.ចិញ្ចឹមត្រីតាមបែ: ចំនួន២៥បែ.(ត្រីអណ្តែង, ប្រា) | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៨.២.ចិញ្ចឹមត្រីតាមស្រះចំនួន១០ស្រះ: ( ត្រីទីឡាព្យ៉ា, ប្រា និងក្រាញ់) | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| **៩-ផែនកាថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍសហគមន៍** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៩.១ភាគទានសមាជិកភាពស.ន | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៩.២ភាគទានប្រចាំឆ្នាំ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៩.៣ភាគទានអាជីវកម្មនេសាទពីអ្នកខាងក្រៅ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| - គម្រោងស្នើសុំថវិកាពីរដ្ឋបាលជលផល , អាជ្ញាធរ និង អង្គការដៃគូ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |

លេខ :……………..

បានឃើញនិងបញ្ជូនមក

លោកនាយសង្កាត់រដ្ឋបាលជលផលកំពង់លួង

" **ដើម្បីពិនិត្យ និង សម្រួល** "

........... .ថ្ងៃទី ខែ ឆ្នាំ២០.....

**មេឃុំស្នាអន្សា**

បានឃើញនិងបញ្ជូនមក

លោកមេឃុំស្នាអន្សា

" **ដើម្បីពិនិត្យ និង សម្រួល** "

……..ថ្ងៃទី… ….ខែ…… …ឆ្នាំ២០…..

**មេភូមិកំពង់ប្រាក់** **មេភូមិបេង** **មេភូមិក្រាំងវែង**

កំពង់ប្រាក់ .ថ្ងៃទី… …ខែ………..ឆ្នាំ២០……

**ប្រធានគណៈកម្មការសហគមន៍នេសាទ**

**កំពង់ប្រាក់**

លេខ :……………..

បានឃើញនិងបញ្ជូនមក

លោកនាយអធិការដ្ឋានរដ្ឋបាលជលផល

ខាងត្បូងបឹងទន្លេសាប" **ដើម្បីពិនិត្យ និង សម្រួល** "

.ថ្ងៃទី ខែ ឆ្នាំ២០

**នាយខណ្ឌរដ្ឋបាលជលផលពោធិ៍សាត់**

លេខ :……………..

បានឃើញនិងបញ្ជូនមក

លោកនាយខណ្ឌរដ្ឋបាលជលផលពោធិ៍សាត់

" **ដើម្បីពិនិត្យ និង សម្រួល** "

........... .ថ្ងៃទី ខែ ឆ្នាំ២០.....

**នាយផ្នែករដ្ឋបាលជលផលក្រគរ**

បានឃើញនិងបញ្ជូនមក

លោកនាយផ្នែករដ្ឋបាលជលផលក្រគរ

" **ដើម្បីពិនិត្យ និង សម្រួល** "

........... .ថ្ងៃទី ខែ ឆ្នាំ២០.....

**នាយសង្កាត់រដ្ឋបាលជលផលកំពង់លួង**

លេខ :……………..

បានឃើញ និងឯកភាព

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលជលផល**

លេខ :……………..

បានឃើញនិងគោរពជូន

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា

ប្រធានរដ្ឋបាលជលផល" **ដើម្បីពិនិត្យ និង សម្រេច**"

………….ថ្ងៃទី ខែ ឆ្នាំ២០

**នាយអធិការដ្ឋានរដ្ឋបាលជលផលខាងត្បូងបឹងទន្លេសាប**